00156500

**Declassified to Public**
**06 September 2012**

ɱ/Nº D32

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the
Courts of Cambodia

| |
|---|
| **បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម** |
| **Certified Copy/Copie Conforme** |
| **ថ្ងៃទី(On/Le)**..07...**ខែ(Month/Mois)**..Dec.. |
| **ឆ្នាំ (Year/Année)**............2007............ |
| **ក្រឡាបញ្ជី/ Greffier** ......SANN RADA |

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**
**002/19-09-2007-ECCC-OCIJ**

# ដីកាចាត់ឲ្យស៊ើបសួរជំនួស
# Rogatory Letter
# Commission Rogatoire

ORIGINAL DOCUMENT
RECEIVED ON 07.12.2007
AT 14:50
BY SANN RADA
ACTING CASE FILE OFFICER

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥ (៥) និង វិធាន ៦២ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ ៖

- ឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ឈ្មោះ **នួន ជា** ឈ្មោះ **អៀង សារី** ឈ្មោះ **ខៀវ សំផន** ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះ**បទល្មើសប្រឆាំងនឹងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩**
- ឈ្មោះ **អៀង ធីរិទ្ធ** ដែលត្រូវដាក់អោយស្ថិតក្រោមការពិនិត្យចំពោះ**បទល្មើសប្រឆាំងនឹងមនុស្សជាតិ**

ដោយមិនអាចបំពេញកិច្ចដែលចាំបាច់ខាងក្រោមដោយខ្លួនឯងបាន

**ហេតុដូច្នេះ សម្រេច**

ផ្ទេរកិច្ចការនេះឲ្យទៅអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលរួមមាន លោក **ស៊ឹម សូរិយ៉ា** និង លោក Steve Heder ដែលត្រូវបំពេញកិច្ចជាក្រុមមួយ ឬ នៅក្នុងករណីចាំបាច់ និងមានការយល់ព្រមពីអ្នកស៊ើបអង្កេតម្នាក់ទៀតអាចបំពេញកិច្ចការនេះតែម្នាក់ឯង ដើម្បីចាត់ការស៊ើបសួរជំនួសតាមបេសកកម្មដែលមានភ្ជាប់មកជាមួយនឹងដីកានេះ។

កំណត់ហេតុបញ្ជាប់បេសកកម្ម រួមទាំងច្បាប់ថតចម្លងដោយមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមមួយច្បាប់ (រួមទាំងឯកសារ ឬភស្តុតាងឧបសម្ព័ន្ធទាំងអស់ផង) ត្រូវប្រគល់មកឲ្យយើងក្នុងរយៈពេល ៦ ខែគិតចាប់ពីថ្ងៃចុះហត្ថលេខាលើដីកាចាត់អោយស៊ើបសួរជំនួសនេះ ។

**បេសកកម្ម**

យើង បង្គាប់មកលោកដែលមានឈ្មោះខាងលើៈ

១- ទំនាក់ទំនងជាមួយអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈមធ្យោបាយសមស្របដើម្បីស្នើអោយមជ្ឈមណ្ឌលនេះសហការក្នុងការពិនិត្យ និង/ឬ ថតចម្លងឯកសារណាមួយ បណ្ណាសារសោតទស្សន៍ ឬ ឯកសារផ្សេងទៀតទាក់ទងទៅនឹងការស៊ើបសួរខាងលើរបស់អង្គជំនុំជម្រះវិសាមញ្ញដែលកំពុងដំណើរការ ដែលស្ថាប័ននេះមាន។

២- ពិនិត្យឯកសារទាំងនោះនៅទីកន្លែង និង/ឬ ស្នើសុំអោយផ្តល់ជូននូវឯកសារថតចម្លងជាក្រដាសឬជាប្រព័ន្ធអេឡិចត្រូនិច ហើយប្រសិនបើចាំបាច់ត្រូវធ្វើការថតចម្លងឯកសារទាំងនោះ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC/CETC

00156502

ឯកសារ/ D32

៣- ត្រូវបង្ហាញជូនលទ្ធផលដល់សហចៅក្រមស៊ើបអង្កេតជាប្រចាំនៅក្នុងកំឡុងពេលបេសកកម្មរបស់ខ្លួន ថាតើមានភស្តុតាងដោះបន្ទុក ឬ ភស្តុតាងដាក់បន្ទុកណាមួយដែលមាននៅក្នុងឯកសារដែលបានពិនិត្យ អាចយកមកពិចារណាដើម្បីដាក់ចូលនៅក្នុងសំណុំរឿង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧

សហចៅក្រមស៊ើបអង្កេត
Co- Investigating Judges
Co-juges d'instruction

MARCEL Lemonde យូ ប៊ុនឡេង

ដីកានេះត្រូវបានតាក់តែងឡើងជាភាសាខ្មែរ និង ភាសាអង់គ្លេស ហើយ នឹងត្រូវបកប្រែជាភាសាបារាំង។